ខុមហ្វ្រែល COMFREL

សៀវភៅកម្រងរូបភាព
PHOTO ALBUM 2021

Published by April 2021

សៀវភៅកម្រងរូបភាព

Photo Album

២០២១

មាតិកា (Content)

សេចក្តីសង្ខេប ----------០១

Executive Summary

កម្មវិធី១. ការអប់រំអំពីប្រជាធិបតេយ្យ និងការបោះឆ្នោត ---------- ០២

Program 1. Education for Democracy and Elections Program

កម្មវិធី២៖ ការពង្រឹងគោលការណ៍ប្រជាធិបតេយ្យ និងការបោះឆ្នោតដោយពិតប្រាកដ ----------០៨

Program 2: Strengthening Genuine Democratic Elections Program

កម្មវិធីទី ៣. ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងវិស័យនយោបាយ----------១៧

Program 3. Women’s Empowerment in Politics Program

កម្មវិធី ៤. ការកំណែទម្រង់អភិបាលកិច្ចប្រជាធិបតេយ្យ----------២៦

Program 4. Democratic Governance Reform Program

កម្មវិធីទី ៥៖ ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន----------២៨

Program 5: Organizational Capacity Development Program

សេចក្តីសង្ខេប

Executive Summary

ក្នុងរយៈពេលមួយឆ្នាំនៃការអនុវត្តគម្រោងរបស់ខ្លួន ខុមហ្វ្រែល រួមទាំងបុគ្គលិក សមាជិកក្រុមប្រឹក្សាភិបាល និងអង្គការសមាជិកគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តសកម្មភាពរបស់ខ្លួនដោយផ្អែកលើគម្រោងផែនការ។ ស្ថានភាពការរាតត្បាតនៃជំងឺកូវីដ-១៩ បានបន្តអូសបន្លាយពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០២១ ហើយមានសភាពធ្ងន់ធ្ងរជាងមុនរហូតឈានដល់ការបិទផ្លូវក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តមួយចំនួន។ ការរាតត្បាតនេះបានបង្កឱ្យមានប៉ះពាល់ដល់ការអនុវត្តសកម្មភាពរបស់ខុមហ្វ្រែល ដែលសកម្មភាពមួយចំនួន ត្រូវបានធ្វើការពន្យារពេល ហើយបុគ្គលិកត្រូវបានតម្រូវឱ្យធ្វើការនៅផ្ទះមួយរយៈ។ ក្នុងស្ថានភាពបែបនេះ ខុមហ្វ្រែលបានសម្រេចចិត្តផ្លាស់ប្តូរវិធីសាស្ត្រមួយចំនួនក្នុងការធ្វើការ ឧទាហរណ៍ៈ ពីសកម្មភាពផ្ទាល់ទៅជាសកម្មភាពតាមអនឡាញ។ ដូច្នេះ ខុមហ្វ្រែលនៅតែទទួលបានសមិទ្ធផលសំខាន់ៗជាច្រើនតាមការគ្រោងទុក។

During the one-year period of its project implementation, COMFREL, its staff members, board members, and member organizations at all levels continued to carry out activities based on the project plan. The situation of the Covid-19 epidemic continued from 2020 until 2021 and was more severe until lockdown in Phnom Penh and some provinces. This affected COMFREL's implementation needed to delay some activities, and staff was required to work at home. With a problematic situation and lockdown, COMFREL decided to change some approaches to work, for example, from direct to online activities. Thus, COMFREL still received multiple significant achievements as planned.

កម្មវិធី១. ការអប់រំលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត

Program 1. Education for Democracy and Elections Program

ផ្នែកប្រព័ន្ធផ្សាព្វផ្សាយបានអនុវត្តសកម្មភាពរបស់ខ្លួនដោយបទបែនដើម្បីសម្រេចលទ្ធផលតាមការរំពឹងទុកទៅតាមផែនការទោះបីជាមានការឆ្លងកូវីតធ្ងន់ធ្ងរនៅកម្ពុជាក៏ដោយ។ កម្មវិធីកិច្ចពិភាក្សាស្តីពីគោលការណ៍ប្រជាធិបតេយ្យ និងការបោះឆ្នោតពិតប្រាកដចំនួន៦ត្រូវបានរៀបចំឡើង បានចប់សព្វគ្រប់ដោយតាមមធ្យោបាយដោយផ្ទាល់ និង ការប្រើប្រាស់ប្រព័ន្ធអនឡាញ។ បើប្រៀបធៀបជាមួយផែនការ ខុមហ្រ្វេលបានធ្វើលើសផែនការចំនួនមួយដែលក្នុងផែនការមានតែចំនួន៥។ អនុសាសន៍ចំនួន ១១៤ បានប្រមូលពីអ្នកចូលរួមក្នុងកិច្ចពិភាក្សាដែលទាក់ទងប្រជាធិបតេយ្យ ការបោះឆ្នោត និងអភិបាលប្រជាធិបតេយ្យ។ កិច្ចពិភាក្សាទាំងនេះមានអ្នកចូលរួមចំនួន៣៣៣នាក់ដែលជាសិស្សមហាវិទ្យាល័យ ព្រះសង្ឃ សង្គមស៊ីវិល បណ្តាញរបស់ខ្លួន កសិករ និងសហគមន៍ដែលមកពីខេត្តកំពត បាត់ដំបង កំពង់ឆ្នាំង កណ្តាល ព្រៃវែង ត្បូងឃ្មុំ និងកំពង់ចាម។ ១៣៦ក្នុងចំណោមអ្នកចូលរួម៣៣៣នាក់គឺជាស្ត្រី និង ៥៩%ជាយុវជន។

The media unit of COMFREL carried out its activities flexibly to achieve expected results as planned although faced the outbreak of the Covid-19 pandemic in Cambodia.

As a result, 6 debates on the principles of democracy and genuine elections were conducted completely by direct and online approach. If compared to the work plan, COMFREL has done more than its expectation, with only 5 debates in the plan. 114 recommendations were collected from the participants related to democracy, elections, and democratic governance. These were attended by 333 participants from university students, monks, CSOs, its network, farmers, and community people and from Kompot, Battambong, Kampong Chhang, Kandal, Prey Veng, Tboung Khmom, Kampong Thom, Koh Kong, Kampong Speu, Phnom Penh, and Kampong Cham province. 136 (41%) of 333 participants were female and 59% were youth

កម្មវិធីផ្សព្វផ្សាយតាមវិទ្យុចំនួន ៣៦៥ ដង (២០៣ ផ្សាយផ្ទាល់ និង ១៤០ ចាក់ឡើងវិញ) នៃកម្មវិធី "VOC" ត្រូវបានរៀបចំឡើងដោយមានវាគ្មិនចូលរួមសរុបចំនួន ៤០៩ នាក់ (ស្ត្រី ៣៥%) ។ ក្នុងការផ្សាយ មានអ្នកហៅចូលកម្មវិធីវិទ្យុចំនួន ១៧៤ នាក់ (ស្រី ៣៤%) នឹងអ្នកបញ្ចេញមតិយោបល់តាមទំព័រហ្វេសប៊ុកចំនួន ១៣៨៦គេណន្យ បានបញ្ចេញមតិ ធ្វើសំណើ និងចោទជាសំណួរផ្ទាល់ទៅកាន់វាគ្មិន។ ក្នុងពេលផ្សាយកម្មវិធីវិទ្យុ ខុមហ្រ្វេល បានផ្សាយផ្ទាល់តាមហ្វេសប៊ុករបស់ខ្លួនចំនួនពីរដងក្នុងមួយថ្ងៃ ដើម្បីពង្រីកការចូលរួមរបស់ទស្សនិកជន។ ជាលទ្ធផល កម្មវិធីវិទ្យុទទួលបានការចូលមើលចំនួន ៣៦៤,៦៦៥ ចំនួនអ្នកចូលចិត្ត៤៨,២៣១ ចំនួនអ្នកចែកបន្ត១៤,៥៧៥ និងចំនួនអ្នកបញ្ចេញមតិយោបល់៤,៧០៦ មតិ តាមរយៈទំព័រហ្វេសប៊ុកខុមហ្រ្វេល។ បន្ទាប់ពីការផ្សាយរួច ខុមហ្រ្វេលបានបង្ហោះចូលក្នុងគេហទំព័ររបស់ខ្លួន ហើយមានអ្នកទាញយកកម្មវិធីវិទ្យុចំនួន ១៨,១៧៦ ។ ក្រៅពីកម្មវិធីវិទ្យុ ខុមហ្រ្វេលមានទំព័រហ្វេសប៊ុកដើម្បីផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងសង្គម

នយោបាយ និងសេដ្ឋកិច្ច។ អត្ថបទចំនួន ៨,០៧៣ ស្តីពីលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងអភិបាលកិច្ចល្អ និងសេចក្តីប្រកាសព័ត៌មានចំនួន ១៨ ត្រូវបានចេញផ្សាយ ហើយវីដេអូតុក្តតាចំនួន ២៤ (វីដេអូតុក្តតាចំនួន ៦ ទាក់ទងនឹងបញ្ហាយេនឌ័រ) ត្រូវបានផលិត និងបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់ខ្លួន។ ការប៉ាន់ប្រមាណនៃអត្ថបទទាំងនេះមានការចូលមើលចំនួន ២,៣៦៥,៣៨៩ អ្នកចូលចិត្តចំនួន ១,៤៨៥,៤៣២ អ្នកចែកបន្តចំនួន ១១៣,០២២ និង អ្នកបញ្ចេញមតិចំនួន ៣២,២៩២។ វីដេអូតុក្តតាទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ ច្បាប់/គោលនយោបាយ អភិបាលកិច្ចល្អ និងសមភាពយេនឌ័រ។ជាលទ្ធផល វីដេអូតុក្តតាទាំងនេះទទួលបានអ្នកមើល ២៦២,២៩៥ អ្នកចូលចិត្តចំនួន ៧១,១៥១ អ្នកចែកបន្តចំនួន ៤,៩៨០ និងអ្នកបញ្ចេញមតិចំនួន ៦២៣។ ខុមហ្វ្រែលក៏បានបង្ហោះវីដេអូតុក្តតាមួយចំនួនកាលពីឆ្នាំមុននៅលើទំព័រហ្វេសប៊ុករបស់ខ្លួន ហើយទទួលបានអ្នកមើលចំនួន ១៧៩,១១៥ អ្នកចូលចិត្តចំនួន ៣០,១២៨ អ្នកចែកបន្តចំនួន ៥,១២៩ និងអ្នកបញ្ចេញមតិចំនួន ៥៥៥។ ទន្ទឹមនឹងនោះដែរមានការចូលមើលគេហទំព័ររបស់ខុមហ្វ្រែល www.COMFREL.org ចំនួន ៧០,៦១២ និងមានអ្នកមើលចំនួន ៣០,៣៨៧ ក្នុងគេហទំព័រសម្លេងម្ចាស់ឆ្នោត "CVV"។ ទំព័រហ្វេសប៊ុករបស់ខុមហ្វ្រែលទទួលបានអ្នកចូលចិត្តចំនួន ១១.៥៩៥ និង អ្នកតាមដានចំនួន ២៣.៥០៩ ហើយបច្ចុប្បន្ន ខុមហ្វ្រែលមានអ្នកតាមដានចំនួន ២៩៦.២៤៥ នាក់ នៅលើទំព័រហ្វេសប៊ុករបស់ខ្លួន។ មានពត៌មានប្រចាំសប្តាហ៍ចំនួន ៥២ ត្រូវបានផ្ញើទៅបណ្តាញរបស់ខ្លួនតាមរយៈE-mail។

365 (203 live and 162 rebroadcast) sessions of "VOC" radio programs were hosted with a total of 409 speakers (35% female), facilitating outreach and public awareness on a multitude of issues. Also, 174 people (34% female) still called and 1,386 people commented on the program to express opinions, make requests, and direct questions to the speakers. During the radio program broadcasting, COMFREL was live on Facebook two times per day to expand the engagement of audiences. Radio program got 364,665 views, 48,231 Likes, 14,575 shares and 4,706 comments through COMFREL Facebook page. After broadcasting and uploading to the website, there were 18,176 downloads of the radio programs from COMFREL's website. In addition to radio programming, COMFREL has a Facebook page to disseminate information regarding society, politics, and economics. 8,073 articles on democracy, elections, and good governance and 18 press statements were released and 24 video animation spots (6 videos related to gender issues) were produced and uploaded on its Facebook page. The estimate of these articles had 2,365,389 engagement (views), 1,485,432 likes, 113,022 shares, and 32,292 comments. These videos were used to educate the voters about elections and democracy, laws/policies and good governance and mainstream gender equality. These video animation spots got 262,295 views, 71,151 likes, 4,980 shares, and 623 comments. COMFREL also posted some video animation spots previous year on its Facebook page and got 179,115 views, 30,128 likes, 5,129 shares and 555 comments. There were 70,612 page views of COMFREL's website www.COMFREL.org, and 30,387 page views of COMFREL's Election Campaign Website "CVV". COMFREL's Facebook page reached 11,595 'likes' and 23,509 "followers" and currently, COMFREL had 296,245 (74% youth and 26% female) on its Facebook page. 52 electoral digest segments were released to its network through the mailing list to 680 people

១.១ ពិភាក្សាអំពីសិទ្ធិក្នុងលទ្ធិប្រជាធិបតេយ្យ និងការណ៍យកិច្ចពលរដ្ឋ 1.1 Debates on Democratic Rights and Civic Duties



កិច្ចពិភាក្សាអំពី គោលការណ៍ប្រជាធិបតេយ្យ និងការបោះឆ្នោតពិតប្រាកដ នៅតាមបណ្តាខេត្តចំនួន៦

The debates on “Principles of Democracy and Genuine Elections” in 6 provinces

១.២. កម្មវិធីវិទ្យុ និងការផ្សាយផ្ទាល់តាមហ្វេសប៊ុក

1.2. Radio program broadcast and Live on Facebook Page

កម្មវិធីវិទ្យុរបស់ខុមហ្វ្រែលដែលមានឈ្មោះថា«សម្លេងសង្គមស៊ីវិល(VoC)» ផ្សាយតាមរយៈស្ថានីយ៍វិទ្យុFM១០៥ ជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៧:៣០ ដល់ ៨:៣០ ព្រឹកពីថ្ងៃច័ន្ទដល់ថ្ងៃសៅរ៍

COMFREL's radio programme "the Voice of Civil Society (VoC)" via FM105 Radio station, broadcasts every day from 7:30 to 8:30 am, Monday to Saturday.

COMFREL was live.
April 3, 2021
See more
48
10 Comments 807 Views
3K
People reached
169
Reactions, comments, and shares
807
3-Second Video Views
Retention curve
View more video details
Like
Comment
Share
Comments
Hide
Most relevant
Pinned Comment
COMFREL · 0:00
Write a comment...
36:23 / 59:21

VOC
Voice of Civil Society
COMFREL was live.
See more
Piseth Nem and 40 others
477 Views
1.9K
People reached
55
Reactions, comments, and shares
477
3-Second Video Views
Retention curve
View more video details
Like
Comment
Share
Comments
Hide
Most relevant
Be the first to leave a comment.
Write a comment...

VOC
Voice of Civil Society
LIVE
COMFREL was live.
October 22, 2021
See more
305
24 Comments 3.5K Views
17.4K
People reached
499
Reactions, comments, and shares
3.5K
3-Second Video Views
Retention curve
View more video details
Like
Comment
Share
Comments
Hide
Most relevant
Pinned Comment
COMFREL · 0:00
Write a comment...

១.៣. ការអប់រំតាមប្រព័ន្ធសង្គមចំរុះអំពីប្រជាធិបតេយ្យ និងការបោះឆ្នោត

1.3. Multimedia education for democracy and elections



វីដេអូតុក្កតា និងអត្ថបទព័ត៌មាន Video Animation Spots and article

កម្មវិធី២៖ ការពង្រឹងគោលការណ៍ប្រជាធិបតេយ្យ និងការបោះឆ្នោតដោយពិតប្រាកដ

Program 2: Strengthening Genuine Democratic Elections Program

កិច្ចប្រជុំចំនួន ២១ស្តីពីលក្ខខណ្ឌអប្បបរមាចំនួន ៦ សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ឆ្នាំ ២០២២ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល គ្រួសារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងស្ថានទូតនានា។

At least 21 meetings on 6 minimum conditions for 2022 commune elections, in cooperation with CSOs with UN family, national and international NGOs, Embassies.

នៅឆ្នាំនេះ ខុមហ្វ្រែលបានបញ្ចប់ការសិក្សាច្បាប់ស្តីពីគណបក្សនយោបាយទាំងស្រុង បានរៀបចំផែនការតស៊ូមតិជាមួយក្រុមបច្ចេកទេសរបស់ខ្លួន ហើយបានដាក់ច្បាប់នេះជារបៀបវារៈក្នុងការជជែកនៅក្នុងវេទិកាធនធ:អ្នកបោះឆ្នោត។ ខុមហ្វ្រែលបានបន្តកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល និងបានតាមដានជាមួយក្រសួងមហាផ្ទៃ (MoI) ទាក់ទងនឹងច្បាប់LANGOs មិនទាន់មានការផ្លាស់ប្តូរបង្ហាញជាសាធារណៈដោយក្រសួងនោះទេ។ ខុមហ្វ្រែលក៏បានដាក់ច្បាប់LANGOs ជារបៀបវារៈនៅក្នុងការជជែកនៅក្នុងវេទិកាធនធ:អ្នកបោះឆ្នោតផងដែរ។ ទន្ទឹមនឹងនេះដែរ ការតស៊ូមតិត្រូវបានធ្វើឡើងតាមរយៈវិធីសាស្ត្រផ្សេងៗគ្នា រួមមានកម្មវិធីវិទ្យុ សុន្ទរកថាជាសាធារណៈ យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម និងវីដេអូតុក្កតា។

This year, COMFREL finished studying the law on political parties completely, set the advocacy plan with its technical team, and put this law as an agenda in the forum on voters' will. COMFREL continued to have meetings with CSOs and follow up with the Ministry of Interior (MoI) related to LANGOs, there have been no changes to this law shown in public by the ministry. COMFREL also put LANGOs on an agenda in the forum on voters' will. At the same time, advocacies were made through different approaches, including radio programme, public speeches, social media campaigns, and video animation spots.

ខុមហ្វ្រែលបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅតាមបណ្តាខេត្តចំនួន ៨ រួមមាន ខេត្តតាកែវ ខេត្តកំពត ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តរតនគិរី។ សិក្ខាសាលាពិគ្រោះយោបល់មាន៧ចំណុចនឹងយកមកជជែកពិភាក្សា រួមមាន ១)ការចុះឈ្មោះអ្នកបោះឆ្នោតនៅក្រៅប្រទេស ២)សិទ្ធិនយោបាយ និងសិទ្ធិឈរឈ្មោះបោះឆ្នោត ៣)ធនធ:អ្នកបោះឆ្នោត និងសិទ្ធិបោះឆ្នោត ៤)សមាសភាព គ.ជ.ប ៥)អព្យាក្រឹតភាពនៃមន្ត្រីរាជការ ៦)តួនាទីប្រព័ន្ធផ្សព្វផ្សាយ និងការពួរសង្គមស៊ីវិល និង៧)ការរំលាយគណបក្សនយោបាយ។

COMFREL conducted the 8 provincial consultation workshops at Takeo, Kampot, Siem Reap, Kampong Cham, Kampong Thom, Preah Vihear, Banteay Meanchey, and Ratanakiri province. There were 7 issues talking in the consultation workshop, including 1) overseas Voter Registration, 2) Political rights and the right to stand for election, 3) voters' will and voting rights, 4) the NEC composition, 5) the neutrality of civil servants 6) the role of the

media and civil society suspension and 7) dissolution of political parties.

របាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ ២០២០ ត្រូវបានផលិត និងបានដាក់សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅការិយាល័យរបស់ខុមហ្វ្រែល ដោយមានអ្នកចូលរួមចំនួន ១៣ នាក់ មកពីស្ថានទូត គណបក្សនយោបាយ គ.ជ.ប និងអ្នកសារព័ត៌មាន។ ការរកឃើញក្នុងរបាយការណ៍នេះជាប្រភពដ៏សំខាន់ដើម្បីតស៊ូមតិជាមួយ គ.ជ.ប និងអ្នកពាក់ព័ន្ធសំខាន់ៗ។ ការរកឃើញទាំងនេះក៏ត្រូវបានចែករំលែកនៅក្នុងកម្មវិធីវិទ្យុ និងកិច្ចប្រជុំជាសាធារណៈផងដែរ។

The report on voter list audition and voter registration 2020 was produced and launched at COMFREL's office with 13 participants from embassies, political parties, the NEC, and media reporters. The findings in the report were an important source to advocate with the NEC and key stakeholders. These were also shared in the radio programmes and public meetings.

ខុមហ្វ្រែលបានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពីដំណើរការចុះឈ្មោះបោះឆ្នោត ជាមួយលេខាធិការខេត្តចំនួន ១៧ ដើម្បីពិភាក្សាអំពីរបៀបត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២១។ ការត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោត បានធ្វើឡើងនៅខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល រតនគិរី កំពង់ធំ ក្រចេះ សៀមរាប មណ្ឌលគិរី ពោធិ៍សាត់ ព្រះសីហនុ ស្ទឹងត្រែង តាកែវ និងខេត្តព្រះវិហារ។ អ្នកសង្កេតការណ៍ ត្រូវបានទទួលស្គាល់ថាជាអ្នកសង្កេតការណ៍ជាតិសម្រាប់ដំណើរការចុះឈ្មោះ គ.ជ.ប។ ក្នុងដំណើរការត្រួតពិនិត្យ ពួកគេត្រូវបានចាត់តាំងឱ្យធ្វើការសង្កេតការណ៍យ៉ាងតិច ០៦ដង ក្នុងរយៈពេល ២ថ្ងៃដំបូងនៃរយៈពេលចុះឈ្មោះ ០២ថ្ងៃ៣ក់កណ្តាលនៃអំឡុងពេល និង២ថ្ងៃចុងក្រោយនៃអំឡុងពេល។ ខុមហ្វ្រែលបានបើកវគ្គបណ្តុះបណ្តាលចំនួនបីដង ស្តីពីការធ្វើសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតដល់អ្នកសង្កេតការណ៍ចំនួន ៣១នាក់ មកពីខេត្តកំពង់ចាម ស្វាយរៀង និងរាជធានីភ្នំពេញ ដើម្បីកសាងសមត្ថភាពលើរបៀបសម្ភាសន៍។ វិធីសាស្ត្រពីរ មនុស្សទៅបញ្ជីនិង បញ្ជីទៅមនុស្ស (P2L និង L2P) នឹងត្រូវបានប្រើដើម្បីត្រួតពិនិត្យ។ ខុមហ្វ្រែលបានរៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាន ស្តីពីការត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោតឆ្នាំ ២០២១ ដែលមានសិក្ខាកាមចំនួន ១៩នាក់ (ស្រី ៩នាក់) ដើម្បីបង្កើនសមត្ថភាពត្រួតពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោត។ វគ្គនេះត្រូវបានបង្រៀន ពីរបៀបប្រើប្រាស់ App ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងដំណើរការចុះឈ្មោះ។ ការត្រួតពិនិត្យការចុះឈ្មោះបោះឆ្នោតបានបញ្ចប់ ហើយសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតបានចាប់ផ្តើម។ ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ដើម្បីធ្វើសវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយប្រើវិធីសាស្ត្រពីបញ្ជីទៅមនុស (L2P) ទៅកាន់ខេត្តចំនួន១០ រួមមាន ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបៃលីន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ភ្នំពេញ ខេត្តកោះកុង និងខេត្តស្វាយរៀង។

COMFREL organized an online meeting on Voter Registration Process with 17 provincial secretaries to discuss how to monitor voter registration in 2021. The registration monitoring was conducted at Banteay Meanchey, Bathambang, Kampong Cham, Kampoung Chhnang, Kampot, Kandal, Ratanakiri, Kampoung Thom, Kratie, Siem Reap, Mondolkiri, Pursat, Preah Sihanouk, Streong Treng, Takeo, and Preah Vihear province. The observers are accredited as national observers for the NEC registration process. In the monitoring process, they are assigned to conduct field observation at least 06 times on the first 2-day of the

registration period, another 2-day middle of the period, and the last 2 days of the period. COMFREL conducted three training sessions on the audit voter list with 31 observers in Kampong Chan, Svay Reang, and Phnom Penh to provide the capacity on how to interview. Two methods (P2L and L2P) would be used to monitor. COMFREL provided an online training session on monitoring the voter registration and voter list 2021 with 19 participants (9 female) to build their capacity to monitor the registration process. This session was taught them how to use App to collect information related to the registration process. The voter registration monitoring finished, and the voter list audit started to kick off. COMFREL deployed observers to conduct the voter list audit with the List to People (L2P) method to 10 provinces, including Takeo, Battambang, Preah Vihear, Oddor Meanchey, Palin, Tboung Kmom, Kampong Cham, Phnom Penh, Koh Kong, and Svay Rieng.

២.១. ការត្រួតពិនិត្យក្របខ័ណ្ឌច្បាប់ រដ្ឋធម្មនុញ្ញ និងការធ្វើរបាយការណ៍

2.1 Constitutional and legal framework review and report



សន្និសីទសារព័ត៌មានស្តីពីលក្ខខណ្ឌអប្បបរមាចំនួន ៦ ត្រូវបានធ្វើឡើងតាមអ៊ីនធឺណិត

A press conference on the 6 minimum conditions was conducted online

កិច្ចប្រជុំជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបង្ហាញពីការរកឃើញទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត

A meeting with the National Election Committee to present its findings on voter registration

២.២. កិច្ចសន្ធនារវាងគ្រប់ភាគី និងការចងបណ្តាញដើម្បីគាំទ្រការបោះឆ្នោត

2.2 Interparty dialogue/Sodality electoral support





កិច្ចប្រជុំ និងការបណ្តុះបណ្តាលជាមួយលេខាខេត្តតាមប្រព័ន្ធអនឡាញ Meeting and training session for provincial secretaries through online

២.៣. កិច្ចសហការដើម្បីការគាំទ្រលើការបោះឆ្នោត 2.3 Sodality electoral support

អង្គការខុមហ្វ្រែលបានសហការជាមួយ អង្គការYRDP បើកវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ និងសូចនាករនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៍

COMFREL, in cooperation with YRDP, conducted a training session on Principles and Indicators of Free and Fair Elections

២.៤. ការអង្កេតការបោះឆ្នោត 2.4 Electoral Monitoring



សិក្ខាសាលាពិគ្រោះយោបល់ត្រូវបានរៀបចំឡើងនៅក្នុងតាមបណ្តាខេត្ត ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួមក្នុងការផ្តល់អនុសាសន៍ និងស្វែងរកការគាំទ្រ

Consultation workshop was conducted in province to give an opportunity to participants to provide recommendations and find support from them

ខុមហ្វ្រែល COMFREL

របាយការណ៍ស្តីពីការសង្កេតការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០២០

ខែ មេសា ឆ្នាំ ២០២១

បើប្រៀបធៀបនឹងផែនការការងារឆ្នាំ ២០២០ ខុមហ្វ្រែលអាចសម្រេចបាន ១០០% នៃផែនការ ព្រោះការស្ទង់មតិលើការចូលរួមរបស់ស្ត្រីក្នុងផ្នែកនយោបាយនៅកម្ពុជា ត្រូវបានផលិត និងដាក់ឱ្យដំណើរការដោយមានអ្នកចូលរួមចំនួន ៥២នាក់ មកពីក្រសួងកិច្ចការនារី គ.ជ.ប គណបក្សនយោបាយ អង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងអ្នកកាសែតក្នុងស្រុក។ ជាលទ្ធផលនៃកិច្ចពិភាក្សា អ្នកចូលរួមបានយល់ដឹងអំពីស្ថានភាពរបស់សកម្មជននយោបាយស្ត្រី និងបញ្ហាប្រឈមរបស់ពួកគេ ហើយបានពិភាក្សាយ៉ាងស៊ីជម្រៅអំពីដំណោះស្រាយដែលអាចធ្វើទៅកើត ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីផ្នែកនយោបាយ។ អ្នកចូលរួមបានសរសើរការខិតខំប្រឹងប្រែងរបស់ខុមហ្វ្រែល ហើយបានសន្យាថានឹងយករឿងនេះទៅពិភាក្សាជាមួយថ្នាក់ដឹកនាំរបស់ខ្លួន។ សារព័ត៌មានVOD, សារព័ត៌មានCAMBOJA និង សារព័ត៌មានRFI បានសម្ភាសជាមួយបុគ្គលិករបស់ខុមហ្វ្រែល ដើម្បីទទួលបានព័ត៌មានលម្អិតនៅចុងបញ្ចប់នៃកិច្ចពិភាក្សា។ ការស្ទង់មតិនេះត្រូវបានផ្សព្វផ្សាយនៅក្នុងកម្មវិធីវិទ្យុ "ស្ត្រីអាចធ្វើបាន" ។

If compared to the work plan 2020, COMFREL could achieve 100% of the plan because the survey on the women political activists' participation in politics in Cambodia was produced and launched with 52 participants from the MoWA, NEC, political parties, CSOs and donors and local journalists. As a result of the discussion, the participants learned and understood the situation of women activists and their challenges and deeply discussed possible solutions to increase women's participation in politics. The participants praised COMFREL's efforts and promised to bring this to talk with their superiors. VOD, CAMBOJA, and RFI interviewed COMFREL's staff for details at the end of the discussion. This survey was disseminated in the "Women Can Do It" radio programme.

នៅឆ្នាំ ២០២១ បុគ្គលិករបស់ខុមហ្វ្រែលបានបញ្ចប់ការសិក្សាលើឯកសារគោលនយោបាយ ដើម្បីលើកកម្ពស់ការចូលរួមផ្នែកនយោបាយរបស់ស្ត្រី និងថ្នាក់សម្រេចចិត្ត ពីប្រទេសផ្សេងទៀត រួមមានប្រទេសស៊ុយអែត រ៉ាន់ដា អ៊ីស្លង់ ន័រវេស និងកាណាដា។ បន្ទាប់ពីបញ្ចប់ការសិក្សា បុគ្គលិករបស់ខុមហ្វ្រែល បានបើកកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ អំពីច្បាប់បោះឆ្នោត និងគោលនយោបាយរបស់ប្រទេសផ្សេងៗ ដែលមានអ្នកចូលរួមចំនួន ១៥នាក់។ ជាលទ្ធផល បុគ្គលិករបស់ខុមហ្វ្រែលបានបង្ហាញការរកឃើញរបស់ខ្លួនទាក់ទងនឹងច្បាប់បោះឆ្នោត។ ក្នុងកិច្ចប្រជុំនោះ អ្នកចូលរួមបានពិភាក្សាយ៉ាងស៊ីជម្រៅអំពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងជំពូកទី៤ (មាត្រា ២៧ និងទី២៨) និងជំពូកទី៦ (មាត្រា៣៩) ហើយពួកគេបានយល់ព្រមប្រើប្រាស់លទ្ធផលនៃកិច្ចពិភាក្សានេះ ដើម្បីធ្វើការតស៊ូមតិរួមគ្នា។ ការតស៊ូមតិជាច្រើនទាក់ទងនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមរយៈកម្មវិធីវិទ្យុ សេចក្តីថ្លែងការណ៍រួម វីដេអូតុក្តតា កិច្ច

ប្រជុំ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ឧទាហរណ៍៖ សេចក្តីថ្លែងការណ៍រួមស្តីពី "ការបង្កើនការប្រុងប្រយ័ត្នដើម្បីការពារអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងតំបន់ចត្តាឡីស័ក និងតំបន់បិទផ្ទាប់" ត្រូវបានធ្វើឡើង។ ជាលទ្ធផល លោក អ៊ុក កុសល ត្រូវបានបណ្តេញចេញពីមុខតំណែង ហើយឧកញ៉ាពីរូបមិនត្រូវបានចាត់វិធានការណាមួយប្រឆាំងពួកគាត់ឡើយ។ ទិវាអន្តរជាតិនារីត្រូវបានប្រារព្ធ និងចូលរួមដោយបុគ្គលិកទាំងអស់របស់ខុមហ្ស្រេល ដើម្បីរំលឹកខួបលើកទី ១១០ នៃទិវានារីអន្តរជាតិ ហើយសេចក្តីថ្លែងការណ៍រួមមួយត្រូវបានចេញផ្សាយជាមួយនឹងអនុសាសន៍សម្រាប់ សម្រាប់រាជរដ្ឋាភិបាល ។

In 2021, COMFREL’s staff finished studying policy papers to promote women’s political participation and decision-making level, in other countries, including Sweden, Rwanda, Iceland, Norway, and Canada. After finishing the study, COMFREL’s staff conducted an online meeting on the study of election laws and other countries’ policies with 15 participants as a working group. As a result, COMFREL’s staff presented its findings related to election laws. In that meeting, participants deeply discussed the Law on Elections of Members of the National Assembly in Chapter 4 (article 27th and 28th) and Chapter 6 (article 39th) and they agreed to use the findings of this discussion to advocate together. Many advocacies related to LEMNA, LEMCC and national policy on gender equality, through the radio programme, joint-statement, video animation spot, meetings and social media. For example: a joint-statement on “Increase Vigilance to Prevent Gender-based violence in Quarantine and Areas under Lockdown” was made. As a result, Mr. Ouk Kosal was fired from his position and two Oknha were not taken any actions against them. International Women’s Day was celebrated and attended by all COMFREL’s staff to commemorate the 110th Anniversary of International Women's Day and a joint-statement was released with recommendations for concrete steps for RGC.

ខុមហ្ស្រេលបានធ្វើសិក្ខាសាលាចំនួនបីតាមការគ្រោងទុករួមមាន សិក្ខាសាលាថ្នាក់ក្រោមជាតិចំនួនពីរតាមអនឡាញ និងសិក្ខាសាលាថ្នាក់ជាតិដោយផ្ទាល់ និងអនឡាញស្តីពី "ការបង្កើនចំនួនស្ត្រីជាអ្នកដឹកនាំផ្នែកនយោបាយ និងថ្នាក់សម្រេចចិត្តនៅកម្ពុជា" ដែលសហការរៀបចំដោយអង្គការខុមហ្ស្រេល ស៊ីលការកម្ពុជា អង្គការយេនឌ័រនិងការអភិវឌ្ឍន៍សម្រាប់កម្ពុជា អង្គការបន្ទាយស្រី និងគណៈកម្មាធិការលើកកម្ពស់ស្ត្រីផ្នែកនយោបាយ។ ពិធីនេះមានអ្នកចូលរួមចំនួន ១៥៣នាក់ មកពីគណបក្សប្រជាជនកម្ពុជា គណបក្សសញ្ជាតិកម្ពុជា គណបក្សខ្មែររួបរួមជាតិ គណបក្សកម្ពុជាស្រលាញ់ជាតិ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សហ៊ុនស៊ីនប៊ិច ក្រសួងកិច្ចការនារី គ.ជ.ប គណៈកម្មាធិការរៀបចំការបោះឆ្នោតខេត្ត សមាជិកក្រុមប្រឹក្សាឃុំ ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និងបណ្តាញរបស់ខុមហ្ស្រេល។ សិក្ខាសាលាទាំងនេះក៏មានការចូលរួមពីអ្នកសារព័ត៌មានមកពី VOD VOA CamboJa, រស្មីកម្ពុជា ហង្សមាស អប្សរា និងមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា។ ជាលទ្ធផលនៃសិក្ខាសាលា អ្នកចូលរួមទាំងអស់ រួមទាំងគណបក្សនយោបាយ មានគំនិតដូចគ្នាក្នុងការអំពាវនាវឱ្យមានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស ក៏ដូចជាការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ដើម្បីនាំមកនូវសមភាពពិតប្រាកដនៅកម្ពុជា។ គណបក្សនយោបាយបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ពួកគេក្នុងការលើកកម្ពស់តួនាទីស្ត្រីនៅក្នុងគណបក្សរបស់ពួកគេ និងដាក់ស្ត្រីជាច្រើនជាបេក្ខជនសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០២២ និងការបោះឆ្នោតរដ្ឋ

សភា ២០២៣៖ ១) គណបក្សប្រជាជននឹងដាក់បេក្ខជនស្ត្រីបន្ថែមទៀត សម្រាប់ការបោះឆ្នោតឃុំសង្កាត់ ២០២២។ តំណាងរូបនេះបានមានប្រសាសន៍ថា ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាទាំងអស់បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើនចំនួនស្ត្រី និងការដោះស្រាយអំពើហិង្សាលើស្ត្រី ២) គណបក្សកម្ពុជាស្រលាញ់ជាតិបានប្តេជ្ញាចិត្តដាក់បេក្ខជនស្ត្រីជាមេឃុំនៅ១០ខេត្តក្រុង ៣) គណបក្សខ្មែររួបរួមជាតិបានប្តេជ្ញាចិត្តដាក់បេក្ខជនស្ត្រី ៣៥% នៅឆ្នាំ ២០២២ និង ៤៥% សម្រាប់ការបោះឆ្នោតរដ្ឋសភា ២០២៣ ៤) គណបក្សប្រជាធិបតេយ្យមូលដ្ឋាន បានប្តេជ្ញាដាក់បេក្ខជនស្ត្រីពី ១ ទៅ ៣ ចំណាត់ថ្នាក់សម្រាប់ ការបោះឆ្នោតឃុំសង្កាត់ ២០២២ ៥)គណបក្សសញ្ញាតិកម្ពុជាបានប្តេជ្ញាដាក់បេក្ខជនស្ត្រីបន្ថែមទៀត សម្រាប់ ការបោះឆ្នោតឃុំសង្កាត់២០២២ និងការបោះឆ្នោតរដ្ឋសភា២០២៣ និង៦) គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ៖ ប្រសិនបើគណបក្សរបស់គាត់ឈ្នះការបោះឆ្នោត ៥០% ស្ត្រីនិង ៥០% បុរស។ តំណាងក្រសួងកិច្ចការនារី៖ លោកជំទាវ ហ៊ូ និមិត្តតា អនុរដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី ក្នុងពិធីបិទសិក្ខាសាលានេះ បានឯកភាព ១០០% ជាមួយនឹងការរកឃើញរបស់ខុមហ្ស្រេល ហើយស្នើឱ្យអ្នកចូលរួមទាំងអស់អនុវត្តរឿងនេះ ដោយមានប្រសាសន៍ថា «យើងទាំងអស់គ្នាត្រូវតែចូលរួមបង្កើតបរិយាកាសអំណោយផល ដើម្បីឱ្យសង្គមកម្ពុជាមានសមភាពយេនឌ័រនៅគ្រប់ទីកន្លែង គ្រប់វិស័យ និងគ្រប់កម្រិត លុះត្រាតែវាកើតចេញពីធនធ:របស់យើងទាំងអស់គ្នា មិនថានៅទីនេះទេ ដែលខ្មែរយើងទាំងអស់គ្នាអាចប្រើប្រាស់។ សក្តានុពលរបស់ស្ត្រី ដែលលើសពី ៥២% នៅក្នុងសង្គមកម្ពុជាគួរត្រូវបានប្រើប្រាស់មិនត្រឹមតែមានអត្ថប្រយោជន៍ដល់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែសមភាពយេនឌ័រនឹងផ្តល់អត្ថប្រយោជន៍លើគ្រប់វិស័យ»។ លោកស្រីបានបន្ថែមថា នៅក្នុងសិក្ខាសាលារបស់យើង ខ្ញុំសូមកោតសរសើរចំពោះកិច្ចសហការរវាងអង្គការខុមហ្ស្រេល អង្គការសីលកាកម្ពុជា អង្គការយេនឌ័រនិងការអភិវឌ្ឍន៍សម្រាប់កម្ពុជា អង្គការបន្ទាយស្រីដែលបានបង្កើតសិក្ខាសាលានេះឡើង ព្រោះវាជាផ្នែកមួយនៃសកម្មភាពជាក់ស្តែងដែលកម្ពុជានឹងមានក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០២២។ បើយើងបានផ្សព្វផ្សាយ យើងនឹងអាចដោះស្រាយឧបសគ្គដែលនាំឱ្យស្ត្រីប្រឈមមុខនឹងហានិភ័យ ដែលមានន័យថា បេក្ខជនទាំងបុរស និងស្ត្រីបានចូលរួមដោយស្មើភាពគ្នា និងបានប្រើប្រាស់សក្តានុពលរបស់ពួកគេក្នុងការអភិវឌ្ឍន៍ប្រទេសរបស់យើង។ លោកស្រីបានបន្ថែមទៀតថា ក្រសួងកិច្ចការនារី បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការលើកកម្ពស់សមភាពយេនឌ័រផ្នែកនយោបាយ និងការសម្រេចចិត្ត ហើយក្រសួងកិច្ចការនារីកំពុងធ្វើការកែលម្អគោលនយោបាយសមភាពយេនឌ័រជាតិរបស់រាជរដ្ឋាភិបាល។ បន្ទាប់ពីសិក្ខាសាលានេះ គណបក្សសញ្ញាតិកម្ពុជា បានស្នើឱ្យមានការជួបជាមួយបុគ្គលិកអង្គការខុមហ្ស្រេល ដើម្បីចែករំលែកព័ត៌មានលំអិតអំពីគោលនយោបាយរបស់ពួកគេ ពោលគឺបង្កើនចំនួនបេក្ខជនស្ត្រីចំនួន ៥០% នៅក្នុងគណបក្សរបស់ពួកគេ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០២២ នាពេលខាងមុខ។ គណបក្សសញ្ញាតិកម្ពុជា បានប្តេជ្ញាក្នុងការបង្កើនចំនួនបេក្ខជន វានៅតែនិយាយថាការជ្រើសរើសត្រូវបានធ្វើឡើងដោយផ្អែកលើសមត្ថភាពរបស់បេក្ខជន។ សាព័ត៌មានVOD បានសម្ភាសសមាជិកក្រុមការងារស្ត្រី និងបានផ្សព្វផ្សាយសិក្ខាសាលាទាំងនេះជាសាធារណៈតាមរយៈវេទិកា VOD ។ ខុមហ្ស្រេលក៏បានផ្សាយនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនដែរ។

COMFREL conducted three workshops as planned; two online sub-national workshops, and one offline national workshop on

"Increasing the number of women leaders in politics and decision-making in Cambodia", co-organized by COMFREL, SILAKA Cambodia, GADC, Banteay Srey organization, and Committee to Promote Women in Politics (CPWP). These were attended by 153 participants from the Cambodian People Party (CPP), Cambodian Nationality Party (CNP), Khmer National United Party (KNUP), the Cambodia National Love Party (CNLP), Grassroots Democracy Party (GDP), Beehive Social Democratic Party (BSDP), FUNCINPEC, the Ministry of Women Affairs (MoWA), NEC, PEC, commune councilors, donors NGOs, community and COMFREL's network. These workshops were also attended by journalists from VOD, VOA, CamboJa, Rasmei Kampuchea Daily, Hang Meas TV, Apsara News, and the Women's Media Centre of Cambodia. As a result of the workshops, all participants including political parties had the same idea of calling for a gender equality policy within the party as well as amending the election laws to bring about real equality in Cambodia. Political parties showed their strong commitment to promote women's role in their parties and place many women as candidate for the upcoming Commune Council Election (CCE) 2022 and National Assembly Election (NAE) 2023: 1) CPP would place more women candidates for CCE 2022. The representative mentioned that all CPP leaders were very focused on increasing the number of women and solving violence against women, 2) CNLP committed place women candidates as commune chief (to be elected) for CCE 2022 in all 10 districts/city, 3) KNUP planned to place women candidates 35% for CCE 2022 and 45% for the NAE 2023, 4) GDP committed to place women candidates from 1 to 3 rank for CCE 2022, 5) CNP committed to place more women candidates for the CCE 2022 and the NAE 2023, 6) BSDP: if his party win the election, 50% women and 50% men and 7) KNP committed to placing at least 30% women candidates and putting from 2-3 rank. Representative of the Ministry of Women's Affairs: Lok Chumteav Hou Nimitta, Undersecretary of State of the MoWA, in closing the workshop, agreed 100% with COMFREL's findings and proposed to all participants to apply this by saying "We must all join to create a conducive environment for Cambodian society to have gender equality everywhere, in all sectors and at all levels, unless it came from the will of all of us, no matter here, that all of us Cambodians could use. The potential of women, who are more than 52% in Cambodian society, has been exhausted, and its use benefits not only one woman, but gender equality would benefit in all areas". She added in our workshop, I commend the collaboration between COMFREL, SILAKA Cambodia, GADC, Banteay Srei, which created this workshop because it was a part of the actual activities that Cambodia would have in the election, Commune/ Sangkat Council Election 2022. So, if we advertised, we would be able to address the barriers that put women at risk, which meant that both male and female candidates were equally involved and have used their potential to develop our country. She also added that the MoWA has worked hard to promote gender equality in politics and decision-making and that the Ministry of Women's Affairs is working to improve the Royal Government's National Gender Equality Policy. After the workshop, the Cambodian Nationality Party (CNP) proposed to have a meeting with COMFREL's staff to share more details about their policy which was to increase the number of women candidates by 50% in their party for the

upcoming commune council election 2022. Although the CNP committed to increasing the number of candidates, it still mentioned that the selection was made based on the candidates' capacity. VOD interviewed women working group members and broadcasted these workshops to the public through the VOD platform. COMFREL also broadcasted them on its Facebook page.

កិច្ចប្រជុំអនឡាញចំនួនបី រួមមានការជជែកតាមអនឡាន និងទិវានារីអន្តរជាតិជាមួយអង្គការ NGO-CEDAW និងមូលនិធិ Heinrich Boell Foundation ដើម្បីធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាព និងបញ្ហាប្រឈមសំខាន់ៗ និងដើម្បីបង្ហាញពីជំហានបន្ទាប់នៃការលើកកម្ពស់សមភាពយេនឌ័រ និងស្ត្រីនៅកម្រិតថ្នាក់សម្រេចចិត្ត ដើម្បីពិភាក្សាអំពីសារៈសំខាន់នៃការប្រើប្រាស់ស្ថិតិយេនឌ័រនៅក្នុងសេដ្ឋកិច្ចឌីជីថល គោលបំណងដើម្បីបង្ហាញពីវិសមភាពយេនឌ័រក្នុងវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា។ ជាលទ្ធផល បុគ្គលិកខុមហ្ស្រែលបានទទួលព័ត៌មានថ្មីៗទាក់ទងនឹងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច និងផែនការជាតិស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ ២០១៩-២០៣០។ មានការរកឃើញថាចំនួនស្ត្រីដែលចូលរួមក្នុងការសម្រេចចិត្តនៅមានកម្រិតទាបនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែដើរតួយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ ។ ស្ថិតិយេនឌ័របានបង្ហាញពីទិន្នន័យច្បាស់លាស់របស់ស្ត្រី និងបញ្ហារបស់ស្ត្រី។ ដូច្នេះស្ថិតិយេនឌ័រគឺជាវិធីសាស្ត្រសំខាន់មួយដើម្បីស្វែងរកមូលហេតុ និងឫសគល់នៃបញ្ហា។ ដើម្បីប្រារព្ធខួបលើកទី ១១០ ទិវាអន្តរជាតិនារី ខុមហ្ស្រែលបានសហការជាមួយអង្គការ NGO-CEDAW និងអង្គការសង្គមស៊ីវិលជាដៃគូបានចេញសេចក្តីថ្លែងការណ៍រួម និងរបាយការណ៍ត្រួតពិនិត្យជាមួយនឹងអនុសាសន៍សម្រាប់រាជរដ្ឋាភិបាលដើម្បីអនុវត្តអនុសាសន៍របស់គណៈកម្មាធិការត្រួតពិនិត្យ CEDAW របស់អង្គការសហប្រជាជាតិ។ សេចក្តីថ្លែងការណ៍រួមក៏ត្រូវបានចេញផ្សាយផងដែរ ស្តីពី "ការបង្កើនការប្រុងប្រយ័ត្ន ដើម្បីទប់ស្កាត់អំពើហិង្សាលើយេនឌ័រ នៅតំបន់ចត្តាឡីស័ក និងតំបន់បិទផ្ទាប់" ដើម្បីអំពាវនាវដល់មន្ត្រីពាក់ព័ន្ធទាំងអស់នៃរាជរដ្ឋាភិបាលកម្ពុជា បង្កើនការប្រុងប្រយ័ត្ន និងចាត់វិធានការទប់ស្កាត់គ្រប់ទម្រង់។ អំពើហឹង្សាលើស្ត្រី កុមារ និងបុគ្គល LGBT+ ដែលអាចកើតឡើងក្នុងអំឡុងពេលដាក់ឱ្យនៅដាច់ពីគេជាកាតព្វកិច្ច និងនៅក្នុងតំបន់ដែលស្ថិតនៅក្រោមការបិទផ្ទប់។ មាន ៨ ចំណុចសំខាន់ៗក្នុងសេចក្តីថ្លែងការណ៍រួម ដើម្បីអំពាវនាវដល់មន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ បង្កើនការប្រុងប្រយ័ត្ន ដើម្បីទប់ស្កាត់អំពើហិង្សាលើយេនឌ័រ។

There were three online meetings, online dialogue and International Women's Day with NGO-CEDAW and Heinrich Boell Foundation (HBF) to update about the key progresses and challenges and to present the next steps of promoting gender equality and women at the decision-making level, to discuss the importance of using gender statistics in the digital economy to highlight gender inequalities in various sectors in Cambodia. As a result, COMFREL staff received updated information regarding promoting women in leadership and governance and a national plan on public administration reform 2019-2030. it was found that the number of women who participated in decision-making was still low. However, women still play an important role in the process of developing the county. The gender statistic showed us the precise data of women and the women's issues. So gender statistics was an important method to find out the root cause of the problem. To mark the 110th International Women's

Day, COMFREL in cooperation with NGO-CEDAW and partner CSOs released a joint statement and monitoring report with recommendations for concrete steps for RGC to take to implement the recommendations of the Committee overseeing the United Nations CEDAW. The joint statement was also released on "Increase Vigilance to Prevent Gender-based violence in Quarantine and Areas under Lockdown", to call on all relevant officials of the Royal Government of Cambodia (RGC) to increase their vigilance and take action to prevent all forms of violence against women, children and LGBT+ individuals who could occur during mandatory quarantine and in areas under lockdown. There were 8 main points in the statement to appeal to all relevant government officials to increase vigilance in order to prevent gender-based violence.

សម្រាប់ផែនការឆ្នាំ២០២១ បុគ្គលិករបស់ខុមហ្វ្រែលបានអនុវត្តទៅតាមផែនការ។ ៥៣ដង (៣៦ ផ្សាយបន្តផ្ទាល់ និង ១៧ ផ្សាយឡើងវិញ) ត្រូវបានរៀបចំតាមរយៈវិទ្យុ FM ១០៥ និងមានវាគ្មិនចំនួន ៥៩ (ស្ត្រី៧៤%) ។ អ្នកហៅចូល និងអ្នកបញ្ចេញមតិយោបល់ចំនួន ៦០នាក់ (ស្ត្រី ៤០%) បានហៅចូលដើម្បីបញ្ចេញមតិ សួរសំណួរទៅកាន់វាគ្មិន និងស្នើរទៅរដ្ឋាភិបាល។ កម្មវិធីវិទ្យុនេះទទួលបានការចូលមើលចំនួន ៤២,១០០ អ្នកចុកចូលចិត្តចំនួន ៥,៥២៤ អ្នកចែកបន្តចំនួន ១,៦៦៨ និងអ្នកបញ្ចេញមតិយោបល់ចំនួន ៥៧២ ។ ខុមហ្វ្រែល បានផលិតវីដេតូក្តាចំនួន៦ ដើម្បីបញ្ជៀបយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រ។

For the 2021 project plan, COMFREL's staff carried out following the plan. 53 sessions (36 live and 17 re-broadcast) were hosted on FM 105 and 59 (74% female) speakers. 60 callers and commenters (40% female) could call in to express their opinions, ask questions to the speakers, and make requests to the government. The radio program received 42,100 views, 5,524 likes, 1,668 shares, and 572 comments. COMFREL produced six video animation spots to maintain gender perspective and promote gender equality.

៣.១ ការធ្វើយុទ្ធនាការ និងបញ្ជុះបញ្ចូលដើម្បីទាមទារអោយមានសមភាពយេនឌ័រ
3.1. Advocacy and Lobbying Campaign to Demand Gender Equality



សកម្មភាពផ្នែកអប់រំ និងយេនឌ័រក្នុងចូលរួមព្រឹត្តិការណ៍សំខាន់ៗដើម្បីជជែក និងពិគ្រោះយោបល់លើបញ្ហាស្ត្រី និងយេនឌ័រជាមួយភាគីពាក់ព័ន្ធ

Activities of Education and Gender unit organizing important events (online) to talk and discuss about the women's issue and gender policy with key stakeholders



៣.៣ កម្មវិធីវិទ្យុ/អនឡាញ«ស្ត្រីអាចធ្វើបាន» និងប្រព័ន្ធផ្សព្វផ្សាយសង្គម

3.3 Online/ Radio call-in show ‘Women Can Do It’ broadcast and Social Media

កម្មវិធីវិទ្យុ/អនឡាញ «ស្ត្រីអាចធ្វើបាន»

“Women Can Do It” Online/Radio Programme



ផ្នែកអប់រំ និងយេនឌ័របានផលិតវីដេអូតុក្តាដើម្បីលើកកម្ពស់សមភាពយេនឌ័រ

Education and Gender Unit produced some video animation spots to promote gender equality

កម្មវិធី ៤. ការកំណែទម្រង់អភិបាលកិច្ចប្រជាធិបតេយ្យ Program 4. Democratic Governance Reform Program

បើប្រៀបធៀបនឹងផែនការការងារឆ្នាំ ២០២០ ខុមហ្វ្រែលអាចសម្រេចបានត្រឹម ៧០% នៃផែនការ ព្រោះ របាយការណ៍ស្តីពីការកំណែទម្រង់លទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតនៅកម្ពុជាមិនត្រូវបានផលិតដូចការគ្រោងទុកទេនោះទេ ដោយសារផលិតករមានបញ្ហាសុខភាពហើយ ខុមហ្វ្រែលមិនអាចរកអ្នកជំនួសបាន។ សម្រាប់របាយការណ៍ឆ្នាំ ២០២១ បុគ្គលិកខុមហ្វ្រែលកំពុងដំណើរការចងក្រងទិន្នន័យដែលប្រមូលបានក្នុងរយៈពេល ១ ឆ្នាំ រួមមាន ការឃ្លាំមើលរដ្ឋាភិបាល ការឃ្លាំមើលសភា ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ និងរបាយការណ៍លទ្ធិប្រជាធិបតេយ្យ។

If compared to the work plan 2020, COMFREL could achieve only 70% of the plan because the 2020 report on Government Watch and Parliament Watch were produced, but the report on democracy and election reform in Cambodia was not produced as planned because a producer got health problem and COMFREL could not find another producer to replace him. For the 2021 reports, COMFREL staff are in the process of compiling data collected for one-year including government watch, parliamentary watch, political gender watch, and democracy report.

ដោយសារការរាតត្បាតជំងឺកូវីត១៩ ការដាក់ពិន្ទុវាយតម្លៃនៃការអនុវត្តរបស់រដ្ឋាភិបាលមិនអាចប្រព្រឹត្តទៅដូចការគ្រោងទុកទេ ដូច្នេះហើយ ខុមហ្វ្រែលបានសម្រេចផ្លាស់ប្តូរវិធីសាស្ត្រពីការដាក់ពិន្ទុវាយតម្លៃនៃការអនុវត្តរបស់រដ្ឋាភិបាល ទៅជាវិធីសាស្ត្រចុះសម្ភាសន៍ផ្ទាល់ជាមួយគ្រួសារ ។ ជាលទ្ធផល ប្រជាពលរដ្ឋប្រមាណ ១៩០នាក់ ដែលមកពីភូមិនីមួយៗនៃ៦ឃុំ បានចូលរួមក្នុងដំណើរការសម្ភាសន៍ផ្ទាល់។ ពួកគេត្រូវបានសម្ភាសន៍ដើម្បីស្វែងយល់អំពីអភិបាលកិច្ចល្អក្នុងមូលដ្ឋាន ផ្តល់ការដាក់ពិន្ទុលើការអនុវត្តអភិបាលកិច្ចល្អនៅក្នុងឃុំរបស់ពួកគេ និងលើកឡើងពីកង្វល់ និងសំណូមពរដល់ឃុំសម្រាប់ដំណោះស្រាយដែលអាចធ្វើទៅបាន។

Due to the Covid-19 pandemic, the people scorecard could not be conducted as planned, so COMFREL decided to change the method from the scorecard to the household visit method (face-to-face interview or dialogue). As a result, about 190 people who were from each village of each commune (6 communes) were engaged in the household visit process. They were interviewed to understand local good local governance, provide their scorecard on the performance of the good governance in their communes, and raise their concerns and requests to commune for possible solutions.

៤.២. ការឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រ 4.2. Parliamentary Watch

ខុមហ្វ្រែលបានផលិតរបាយការណ៍ប្រចាំឆ្នាំ២០១៩ ស្តីពីការសង្កេត រដ្ឋសភា និងតំណាងរាស្ត្រ និងបានបង្ហោះលើគេហទំព័ររបស់ខ្លួន។

COMFREL produced a 2019 annual report on Parliamentary Watch and uploaded on its website.

កម្មវិធីទី ៥៖ ការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន Program 5: Organizational Capacity Development Program

បើប្រៀបធៀបទៅនឹងផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងផែនការគម្រោងរបស់ខុមហ្ស្រេល សម្រេចបាន ៩០% ដោយសារតែបុគ្គលិកបានទទួលការអភិវឌ្ឍន៍សមត្ថភាព រួមមានការសរសេររបាយការណ៍ QuickBooks និងវីដេអូតុក្តាដូចការគ្រោងទុក។ ទោះយ៉ាងណាក៏ដោយខុមហ្ស្រេលមិនបានសិក្សាមុខវិជ្ជាមួយចំនួន រួមទាំងការបង្កើតវីដេអូតុក្តាពីខាងក្រៅ ការស្រាវជ្រាវផ្អែកលើកស្តុតាង និងការណែនាំអំពីការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ។ ខុមហ្ស្រេលមិនអាចរកអ្នកខាងក្រៅដើម្បីផ្តល់សមត្ថភាពលើការបង្កើតវីដេអូតុក្តាទេ ហើយវគ្គសិក្សានេះត្រូវការពេលវេលាច្រើនដើម្បីរៀន។ វគ្គបណ្តុះបណ្តាលស្តីពីការស្រាវជ្រាវផ្អែកលើកស្តុតាង និងការណែនាំអំពីការអនុវត្តគោលនយោបាយហិរញ្ញវត្ថុត្រូវបានខកខានដោយសារតែការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីត១៩ ហើយនៅពេលដែលស្ថានភាពត្រលប់មកវិញ បុគ្គលិកត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបញ្ចប់សកម្មភាពសដើម្បីសម្រេចទៅតាមផែនការរបស់ខ្លួន។ បុគ្គលិកបានអភិវឌ្ឍសមត្ថភាព និងជំនាញបន្ថែមទៀតលើការសរសេររបាយការណ៍ របៀបប្រើប្រាស់ QuickBooks សម្រាប់ការងារហិរញ្ញវត្ថុ និងការផលិតវីដេអូតុក្តា។ ខុមហ្ស្រេល បានបង្កើតគោលនយោបាយធនធានមនុស្ស និងគោលការណ៍ណែនាំ M&E បានចប់រួចរាល់ទាំងស្រុងតាមការគ្រោងទុក។ គោលនយោបាយដែលមិនទាន់មានសុពលភាព ត្រូវបានធ្វើបច្ចុប្បន្នភាព និងកែសម្រួលរួចហើយ ដូច្នេះបច្ចុប្បន្ន ខុមហ្ស្រេល កំពុងប្រើប្រាស់គោលនយោបាយដែលបានធ្វើបច្ចុប្បន្នភាពរួចនៅក្នុងស្ថាប័នរបស់ខ្លួន។ បុគ្គលិករបស់ខុមហ្ស្រេល ត្រូវបានទទួលការបណ្តុះបណ្តាលទាក់ទងនឹងគោលនយោបាយធនធានមនុស្សចំនួនពីរលើក។ ខុមហ្ស្រេល មានគោលការណ៍ណែនាំ និងប្រព័ន្ធ M&E សម្រាប់ការប្រើប្រាស់នៅផ្ទៃក្នុងរបស់ខ្លួន ហើយនឹងរួមចំណែកដល់ការកែលម្អការអនុវត្តរបស់ក្រុម M&E ផងដែរ។ ទោះបីជារបាយការណ៍ស្តីពីគោលការណ៍ណែនាំ M&E ត្រូវបានបញ្ចប់ក៏ដោយ បុគ្គលិករបស់ខុមហ្ស្រេលមិនទាន់បានទទួលការបណ្តុះបណ្តាលនៅឡើយទេ ហើយវគ្គបណ្តុះបណ្តាលនឹងគ្រោងធ្វើនៅខែកុម្ភៈ ឆ្នាំ ២០២២ ដូច្នេះ ខុមហ្ស្រេលមិនអាចវាស់វែងពីអត្ថប្រយោជន៍នៃគោលការណ៍ណែនាំ M&E បានទេនៅពេលនេះ។ ខុមហ្ស្រេល បានរៀបចំកិច្ចប្រជុំប្រចាំសប្តាហ៍ ក្នុងចំណោមក្រុមគ្រប់គ្រងដើម្បីធ្វើបច្ចុប្បន្នភាពសកម្មភាព បញ្ហាប្រឈម ហិរញ្ញវត្ថុ និងការងាររបស់អង្គការ។ កិច្ចប្រជុំប្រចាំសប្តាហ៍ក៏ត្រូវបានធ្វើឡើងដើម្បីដោះស្រាយកិច្ចការបន្ទាន់មួយផងដែរ ឧទាហរណ៍៖ បុគ្គលិករបស់ខុមហ្ស្រេលម្នាក់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកវិភាគនយោបាយម្នាក់ដែលបានរក

ឃើញឆ្លងកូវីត។ កិច្ចប្រជុំបានសម្រេចឱ្យបុគ្គលនេះទៅធ្វើតេស្តរកកូវីត ហើយក្នុងអំឡុងពេល ១៤ ថ្ងៃ បុគ្គលិកបានធ្វើការពីផ្ទះ។ កិច្ចប្រជុំប្រចាំខែ (កិច្ចប្រជុំបុគ្គលិក) ធ្វើឡើងដើម្បីចែករំលែកស្ថានភាពបុគ្គលិកអំឡុងពេលការរីករាយជាលជំងឺកូវីត បោះឆ្នោតជ្រើសរើសតំណាងបុគ្គលិក ជូនដំណឹងដល់បុគ្គលិកធ្វើការពីផ្ទះ អប់រំបុគ្គលិកអំពីរបៀបការពារខ្លួនពីជំងឺកូវីត ធ្វើបច្ចុប្បន្នភាពធ្វើការ និងធ្វើការសម្រេចចិត្តសម្រាប់ការដកបុគ្គលិក។ សវនករហិរញ្ញវត្ថុខាងក្រៅត្រូវបានជួលឱ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុរបស់ខុមហ្ស្រែល។ ខុមហ្ស្រែលបានធ្វើការឆ្លុះបញ្ចាំងបុគ្គលិកប្រចាំឆ្នាំនៅខេត្តព្រះសីហនុ ដើម្បីពិនិត្យការអភិវឌ្ឍន៍អង្គភាព ពិភាក្សាអំពីផែនការយុទ្ធសាស្ត្រឆ្នាំ២០២២ និងកសាងសាមគ្គីភាពរវាងបុគ្គលិកខុមហ្ស្រែល។ គោលនយោបាយធនធានមនុស្សថ្មីក៏ត្រូវបានបង្ហាញដល់បុគ្គលិកផងដែរ។ ខុមហ្ស្រែលបានប្រើប្រាស់ឧបករណ៍ Octagon ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍អង្គការប្រចាំឆ្នាំរបស់ខ្លួន ដោយមានការចូលរួមពីបុគ្គលិកខុមហ្ស្រែល រួមទាំងបុគ្គលិកនៅក្នុងការិយាល័យកណ្តាល អ្នកស្ម័គ្រចិត្ត លេខាធិការខេត្ត ក្រុមប្រឹក្សាខុមហ្ស្រែល។ ជាលទ្ធផលនៃការឆ្លុះបញ្ចាំង ខុមហ្ស្រែលបានសិក្សាបន្ថែមអំពីចំណុចខ្វះខាត និងយល់ពីអ្វីដែលគួរធ្វើដើម្បីកែលម្អ។ ជ្រុងទាំង៨ នៃឧបករណ៍Octagon ត្រូវបានដាក់ពិន្ទុដោយបុគ្គលិក ហើយជាលទ្ធផលទទួលបាន ៤.៩៤ ជាមធ្យម (ពិន្ទុ ១-៧)។ តួលេខនេះបានបង្ហាញថា ខុមហ្ស្រែលបានបំពេញការងាររបស់ខ្លួនល្អ។

If compared to the staff capacity development plan and project plan, COMFREL could achieved 90% because staff received the capacity development including report writing, QuickBooks and video animation spot (internal training) as planned. However, COMFREL didn't study some subjects including creation of digital caricature/video animation, evidence-based research and mentoring on implementation of financial policy. COMFREL couldn't find outsourcing to provide capacity on creation of digital caricature/video animation and this course needed much time to learn. The course on evidence-based research and mentoring on implementation of financial policy were missed because of the outbreak of the Covid-19 pandemic and when the situation was back, it was short that staff pay much attention on finishing the activities against the plan. Staff developed more capacity and skill on report writing, how to use QuickBooks for financial work and video animation production. COMFREL produced the HR policy and M&E guideline completely as planned. Some policies were out of dead have already updated and revised, so COMFREL currently is using updated policies in its organization. COMFREL's staff was oriented related to new HR policy twice by HR consultant and COMFREL administrator at staff reflection (staff retreat). COMFREL had M&E guideline and system for using its internal organization and it would also contribute to improving the M&E team's implementation. Although report on M&E guideline was finished, COMFREL' staff have not received coaching yet and training session was planned to conduct in February 2022, so COMFREL can't measure the benefit from M&E guideline now. However, now COMFREL has its M&E guideline and system. COMFREL organized weekly meetings (Excom Meeting) among the management team to update its activities, challenges, finance and organizational work. The weekly meeting was also conducted to solve an urgent task, for

example, one staff of COMFREL worked closely with a political analyst who found Covid-19. The meeting decided that this person went to test for Covid-19 and during 14-day, staff worked from home. Monthly meetings (staff meetings) were conducted to share the situation of staff during the Covid-19, to vote for staff representative, to inform the staff to work from home, educate staff on how to protect themselves from Covid-19, to update COMFREL's work and make a decision for a staff retreat. External finance auditor was hired to conduct COMFREL finance. COMFREL conducted staff reflection (staff retreat) in Sihanoukville province to review organizational development, discuss a strategic plan for 2022, and build solidarity among COMFREL staff. A new HR policy was also presented to the staff. COMFREL used Octagon to reflect its annual organizational development and COMFREL staff including all staff in the central office, volunteers, provincial secretaries, board of COMFREL, were attended. As a result of reflection, COMFREL learned more about the shortcomings and understood what should do to improve them. 8 corners of Octagon were scored and received 4.94 on average (1-7 score). This figure showed that COMFREL had a good performance on 8 corners.